**Declassified to Public**
**06 September 2012**

E28/2/L



**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

សំណុំរឿងក្តីលេខ : ០០១/១៨-០៧-២០០៧-អវតក/អជសង

កាលបរិច្ឆេទរបស់ឯកសារ : ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩

ភាគីដាក់ជូនសារណា : សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១

ភាសាដើម : ភាសាអង់គ្លេស

ប្រភេទឯកសារ : សាធារណៈ

---

# ការឆ្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ចំពោះចម្លើយតបរបស់សហមេធាវីការពារក្តីស្តីពីបញ្ជីឈ្មោះសាក្សីនិងបញ្ជីឈ្មោះឯកសារ

---

<u>ដាក់ជូនដោយ</u>:

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក Karim A. A. KHAN
កញ្ញា ទី ស្រ៊ុនណា
លោក Alain WERNER
លោកស្រី Brianne McGONIGLE

<u>ជូនចំពោះ</u>:

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

<u>ចម្លងជូន</u>:

**ជនជាប់ចោទ:**

លោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ:**

លោក ការ សាវុត្ថ
លោក François ROUX

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជាលាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ
លោក Alex BATES

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 04 / 2009
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

E28/2/1

០០១/១៨-០៧-២០០៧-អវតក/អជសង

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

លោក Pirre-Olivier SUR

I. **សេចក្តីផ្តើម**

១. នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ("CPG-1") បានដាក់សេចក្តីសន្និដ្ឋានដែលមានចំណងជើងថា: "បញ្ជីឈ្មោះឯកសារនិងឈ្មោះសាក្សីដែលត្រូវបានកោសលុបរួច" ("បញ្ជីឈ្មោះសាក្សី")[1]។ នៅក្នុងផ្នែកនៃសេចក្តីសន្និដ្ឋាននេះ CPG-1បានស្នើដល់អង្គជំនុំជម្រះសាលាដំបូងដោយក្តីគោរពសុំឱ្យកោះអញ្ជើញ *"អ្នកជំនាញទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ក [ដើម្បី]... ដើម្បីផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"*[2]។ អ្នកជំនាញចំនួនពីររូបក្នុងចំណោមអ្នកជំនាញទាំងឡាយ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ក គឺវេជ្ជបណ្ឌិត Christopher Staker (លេខ៣) និងអ្នកស្រី ភួង ផាម (លេខ៤)[3]។

២. នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ សហមេធាវីការពារក្តីឱ្យជនជាប់ចោទបានដាក់ចម្លើយតប ដែលមានចំណងជើងថា: "ចម្លើយតបរបស់សហមេធាវីការពារក្តីទៅនឹងបញ្ជីឈ្មោះសាក្សីនិងឯកសារទាំងឡាយដែលត្រូវបានកោសលុបដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១" ("ចម្លើយតប")[4]។ សហមេធាវីតំណាង CPG-1 បានទទួលការបកប្រែឯកសារជាភាសាអង់គ្លេស កាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩[5]។ ដោយមានចម្លើយតបចំពោះសាក្សីជាអ្នកជំនាញដែលស្នើសុំដោយ CPG-1 នោះ

---

[1] រឿងក្តី កាំង ហ្កេកអ៊ាវ, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ង, បញ្ជីឈ្មោះសាក្សីនិងឯកសាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩, Doc. No. E5/12។

[2] *ដូចជើងទំព័រខាងលើ* នៅកថាខណ្ឌ១៩។

[3] *ដូចជើងទំព័រខាងលើដែរ។*

[4] រឿងក្តី កាំង ហ្កេកអ៊ាវ, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ង, ចម្លើយតបរបស់ក្រុមមេធាវីការពារទៅនឹងបញ្ជីឈ្មោះសាក្សី និងឯកសារទាំងឡាយដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១, Doc. No. E28/1។

[5] រឿងក្តី កាំង ហ្កេកអ៊ាវ, សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ង, ចម្លើយតបរបស់ក្រុមមេធាវីការពារទៅនឹងបញ្ជីឈ្មោះសាក្សី និងឯកសារទាំងឡាយដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩, Doc. No. E28/1។

សហមេធាវីការពារក្តី នៅក្នុងចម្លើយតបរបស់ខ្លួន មានបំណងលើកឡើងនូវបញ្ហាថ្មីស្រឡាង និងដាច់ដោយឡែក ដែលមិនមានបង្ហាញនៅក្នុងបញ្ជីឈ្មោះសាក្សីនោះទេ។

៣. ចម្លើយតបនេះមាននិយាយភាគច្រើនតែអំពីតួនាទីដែលមានកំណត់ របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលដំណើរការនីតិវិធីនៅចំពោះមុខអ.វ.ត.ក។ ចម្លើយតបនេះបានលើកឡើងថា ការអនុវត្តបានល្អប្រកបដោយយុត្តិធម៌ត្រូវរារាំងសហមេធាវីតំណាងCPG-1 មិនឱ្យកោះអញ្ជើញវេជ្ជបណ្ឌិត Staker និងវេជ្ជបណ្ឌិត ផាម ក្នុងឋានៈជាសាក្សីដើម្បីពិភាក្សាលើបញ្ហាផ្តន្ទាទោសទេ[6]។ អាស្រ័យហេតុនេះហើយទើប សហមេធាវីការពារក្តីបានស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យបដិសេធសំណើរបស់CPG-1 សុំកោះអញ្ជើញសាក្សីជាអ្នកជំនាញទាំងពីររូប ហើយលើសពីនេះទៀត សហមេធាវីការពារក្តីបានស្នើសុំឱ្យមានការហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណី កុំឱ្យដាក់ជូនអ្វីមួយ ដែលពាក់ព័ន្ធនឹងបញ្ហាផ្តន្ទាទោស[7]។

៤. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងមិនរង់ចាំការឆ្លើយតបរបស់CPG-1 ចំពោះចម្លើយតបរបស់សហមេធាវីការពារក្តីនោះទេ និងបានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការកោះអញ្ជើញសាក្សីនិងអ្នកជំនាញនានា[8]។ នៅក្នុងសេចក្តីសង្ខេបនោះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់CPG-1 សុំឱ្យកោះអញ្ជើញទាំងវេជ្ជបណ្ឌិត Staker ទាំងវេជ្ជបណ្ឌិត ផាម ក្នុងឋានៈជាសាក្សី[9]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងមិនបាននិយាយអំពីបញ្ហា ទីពីរដែលពាក់ព័ន្ធនឹងវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការផ្តន្ទាទោសនោះទេ។

---

[6] *ដូចជើងទំព័រខាងលើ* នៅកថាខណ្ឌ២-៣។

[7] *ដូចជើងទំព័រខាងលើ* នៅកថាខណ្ឌ២១។

[8] រឿងក្តី កាំង ហ្គេកអ៊ាវ, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និងលើសំណើរបស់ភាគីសុំស្តាប់ចម្លើយសាក្សីនិងអ្នកជំនាញ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, Doc. No. E40។

[9] *ដូចជើងទំព័រខាងលើ* នៅកថាខណ្ឌ៤-៥។

៥. នៅក្នុងអំឡុងពេលសវនាការបឋមកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ជាដំបូង សហមេធាវីការពារក្តីមានបំណងលើកឡើងពីបញ្ហាសំខាន់នេះ ដោយនិយាយថា *"សហមេធាវីការពារក្តីនឹងជជែកតវ៉ាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់ទីបញ្ចប់ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីប្រាថ្នាឱ្យមានការកោះអញ្ជើញសាក្សីទាំងឡាយណា ដែលនឹងមកជជែកការពារអំពីការផ្តន្ទាទោសដែលជនត្រូវចោទអាចនឹងទទួលបាន"*[10]។ សហមេធាវីការពារក្តីបានតវ៉ាថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនរាប់បញ្ចូលនូវសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋាន ទៅលើបញ្ហានៃការផ្តន្ទាទោសនោះទេ ដែលនេះបង្ហាញអំពីចរិតលក្ខណៈរបស់ "គោលការណ៍គ្រឹះនៃច្បាប់រដ្ឋប្បវេណី"[11]។

៦. ការិយាល័យសហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២,៣ និង ៤) ចំនួនបួនរូប ក៏បានគូសបញ្ជាក់ផងដែរអំពីការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធនឹងតួនាទីដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវដើរតួ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានជូនទៅតុលាការ ទាក់ទិននឹងបញ្ហានៃការផ្តន្ទាទោស [12]។

៧. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ("CPG-1") លោក Karim A. A. Khan បានលើកឡើងអំពីមូលហេតុនៃពីការកោះអញ្ជើញលោក ក្នុងឋានៈជាសាក្សីជាអ្នកជំនាញ ក៏ដូចជាបញ្ហានានាដែលត្រូវបានលើកឡើងដោយសហមេធាវីការពារក្តី ពាក់ព័ន្ធនឹងវិសាលភាពដែលដើមបណ្តឹងរដ្ឋប្បវេណីគួរតែត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានទៅលើបញ្ហានៃការផ្តន្ទាទោស[13]។

---

[10] រឿងក្តី កាំង ហ្គេកអ៊ាវ, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, កំណត់ហេតុជាលាយលក្ខណ៍អក្សរសវនាការបឋម, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, អសាធារណៈ, Doc. No. E1/4.2, ទំព័រ ៨។

[11] *ដូចដើងទំព័រខាងលើ* នៅទំព័រ៨។ សូមមើលផងដែរ រឿងក្តី កាំង ហ្គេកអ៊ាវ, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, កំណត់ហេតុជាលាយលក្ខណ៍អក្សរសវនាការបឋម, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, សាធារណៈ, Doc. No. E1/4.1, ទំព័រ៧។

[12] *ដូចដើងទំព័រខាងលើ* នៅទំព័រ៩-១៥។ សូមមើលផងដែរ រឿងក្តី កាំង ហ្គេកអ៊ាវ, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, កំណត់ហេតុជាលាយលក្ខណ៍អក្សរសវនាការបឋម, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, សាធារណៈ, Doc. No. E1/4, ទំព័រ៨-១៥។

[13] *ដូចដើងទំព័រខាងលើ* នៅទំព័រ១៦-២១។

## II. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស

៨. ក្នុងចម្លើយតបរបស់ខ្លួន មេធាវីការពារក្តីព្យាយាមព្យាយាមបញ្ចុះបញ្ចូលអង្គជំនុំជម្រះសាលាដំបូងឱ្យសម្រេចបញ្ហាទូលំទូលាយនៃសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់សេចក្តីសន្និដ្ឋានអំពីបញ្ហាផ្តន្ទាទោស។ ជាក់ស្តែងណាស់ថា មេធាវីការពារក្តីកំពុងតែស្នើសុំឱ្យមានការសម្រេចលើបញ្ហាដែលហួសពីវិសាលភាពនៃការស្នើសុំរបស់CPG-1។ ក្នុងកាលៈទេសៈបែបនេះ CPG-1 សូមដាក់ដោយគោរពថា សំណើរបស់សហមេធាវីការពារក្តីគឺជាសំណើដែលមិនសមស្រប ដោយសារតែសំណើនេះសុំឱ្យសម្រេចលើបញ្ហា ដែលមិនមានលើកឡើងក្នុងបញ្ជីសាក្សីដែលដាក់ដោយCPG-1 កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩។ សំណើផ្ទាល់មាត់លើប្រធានបទនេះក៏មិនដែលបានធ្វើជាផ្លូវការដោយមេធាវីការពារក្តីក្នុងអំឡុងពេលសវនាការបឋមដែរ។ ដូច្នេះ CPG-1 សូមស្នើដោយគោរពកុំឱ្យមានការសម្រេចលើបញ្ហាអ្វីមួយ ដោយមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ភាគីដើម្បីបង្ហាញទស្សនរបស់ខ្លួនលើបញ្ហាសំខាន់ និងដាច់ដោយឡែក ដូចដែលមានចែងក្នុងវិធាន[14]។

## III. សំណើ

៩. ចំពោះហេតុផលដែលបានលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សូមអង្វរអង្គជំនុំជម្រះសាលាដំបូងកុំឱ្យយកចិត្តទុកដាក់ចំពោះសេចក្តីសន្និដ្ឋាន ដែលមាននៅក្នុងចម្លើយតបរបស់សហមេធាវី ការពារក្តីដែលទាក់ទងនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការរួមចំណែកក្នុងកិច្ចពិភាក្សាលើការផ្តន្ទាទោស។ ផ្ទុយទៅវិញ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សូមស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូង សុំអនុញ្ញាតិឱ្យមានការធ្វើសេចក្តីសង្ខេបលើបញ្ហានេះបន្ថែមទៀត។

[14] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧វិសោធនកម្មលើកទី៣, សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក, មាត្រា៨.៣។

00305140

E28/2/1



សូមដាក់ជូនដោយសេចក្តីគោរពពី

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ១)

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩

Po DMK Ty Srinna　　　Po DMK Alain Werner

ទី ស្រីនណា　　　Alain Werner